# សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

# សាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី

ពិនិត្យមុននឹងបញ្ជូនចេញ

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

សម័យប្រជុំលើកទីម្ភៃបួន

២៤ កញ្ញា ២០១៣

លោកប្រធាន ឯកឧត្តម អស់លោក និង លោកស្រី ជាទីគោរពរាប់អាន

ខ្ញុំមានកិត្តិយសសូមថ្លែងទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីផ្តល់នូវសេចក្តីបរិយាយសង្ខេបមួយអំពីវិវដ្ត និងបញ្ហាប្រឈម នៅក្នុងការលើកកម្ពស់ និង ការពារសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅក្នុងរយៈពេល ១២ ខែ ចាប់តាំងពីខ្ញុំបានថ្លែងការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សកាលពីឆ្នាំកន្លងទៅ។ សេចក្តីថ្លែងការណ៍នេះ ផ្អែកជាសំខាន់លើព័ត៌មាន ដែលខ្ញុំទទួលបាននៅក្នុងបេសកកម្មចំនួនពីររបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា ព័ត៌មានដែលបានទទួលពីប្រភពផ្សេងៗដែលឯករាជ្យ និងដែលអាចជឿទុកចិត្តបាន និងលិខិតដែលខ្ញុំបានទទួលពីរដ្ឋាភិបាល។

ជាបឋម ខ្ញុំសូមធ្វើការកត់សំគាល់ថា ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលទទួលសេចក្តីពន្យល់ពីរដ្ឋាភិបាល តបទៅនឹងរបាយការណ៍របស់ខ្ញុំ នៅឆ្នាំនេះ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារការផ្ញើលិខិតទាំងនេះមកខ្ញុំមានការយឺតយ៉ាវខ្លាំងសម្រាប់ការដាក់បញ្ចូលក្នុងរបាយការណ៍របស់ខ្ញុំ ទើបសេចក្តីពន្យល់ទាំងនោះ ត្រូវបានរក្សាឲ្យមានជាឯកសារ G សម្រាប់ជាឯកសាររបស់អ្នក។

ចាប់តាំងពីខ្ញុំទទួលបានការតែងតាំងពីក្រុមប្រឹក្សាសិទ្ធិមនុស្ស ជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩ ខ្ញុំបានធ្វើរបាយការណ៍សំខាន់ធំៗចំនួនបួន ដែលមានការការវិភាគគ្រប់ជ្រុងជ្រោយអំពីស្ថានភាពសិទ្ធិមនុស្ស ហើយបានដាក់ចេញជាបន្តបន្ទាប់នូវអនុសាសន៍ក្នុងន័យស្ថាបនា ដែលបានធ្វើឡើងដើម្បីជួយដល់រដ្ឋាភិបាលក្នុងការអនុវត្តរបៀបវារៈកំណែទម្រង់ និងដំណើរការប្រជាធិបតេយ្យនីយកម្ម។ ដោយបានផ្តោតលើកំណែទម្រង់ប្រព័ន្ធតុលាការ សភា និងការបោះឆ្នោត និងលើផលប៉ះពាល់សិទ្ធិមនុស្សដោយសារសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ខ្ញុំមានអារម្មណ៍ថា ពេលវេលាបានដល់ហើយក្នុងការពិនិត្យតាមដានអំពីវឌ្ឍនភាពលើការអនុវត្តអនុសាសន៍ដែលបានធ្វើនៅក្នុងរបាយការណ៍ទាំងនេះ និងកំណត់អំពីបញ្ហាប្រឈមទាំងឡាយដែលនៅសេសសល់។ អាស្រ័យហេតុនេះ ជាជាងការទទួលយករឿងសិទ្ធិមនុស្សថ្មី ខ្ញុំបានផ្តោតដំណើរបេសកកម្មពីរចុងក្រោយរបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា ដែលបេសកកម្មមួយ បានធ្វើឡើងក្នុងខែធ្នូ ឆ្នាំ២០១២ និងបេសកកម្មមួយទៀតក្នុងខែឧសភា ឆ្នាំ២០១៣ លើការឃ្លាំមើលស្ថានភាពសិទ្ធិ មនុស្សនៅក្នុងប្រទេសកម្ពុជា និងលើការតាមដានការអនុវត្តរបាយការណ៍កន្លងមករបស់ខ្ញុំ។ ខ្ញុំបានអនុវត្តភារកិច្ចនេះ ដោយប្រកាន់ខ្ជាប់នូវស្មារតី ដូចដែលខ្ញុំ

តែងតែបានអនុវត្តកន្លងមក ដោយគោរពចំពោះលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងអាណត្តិរបស់ខ្ញុំ គឺក្នុងន័យស្ថាបនា ដែលបានធ្វើឡើងដើម្បីជួយដល់រដ្ឋាភិបាល ក្នុងការកំណត់វិស័យនៃវឌ្ឍនភាព ក៏ដូចជាបញ្ហាប្រឈមទាំងឡាយដែលនៅសេសសល់ ។

គួរឲ្យសោកស្តាយ បេសកកម្មរបស់ខ្ញុំមកកាន់ប្រទេសនេះក្នុងខែធ្នូ ឆ្នាំ២០១២ ត្រូវបានទទួលស្វាគមន៍ក្នុងសភាពមួយសោះកក្រោះ ដែលនៅក្នុងអំឡុងពេលនោះ មិនមានសមាជិកជាន់ខ្ពស់ណាម្នាក់មានពេលជួបជាមួយខ្ញុំឡើយ។ កន្លងមក ខ្ញុំបានទទួលរងសំដីមិនគួរគប្បីមួយចំនួនសំដៅលើរូបខ្ញុំផ្ទាល់លក្ខណៈជាបុគ្គលផងដែរ។ នេះគឺជាទង្វើដែលគួរឲ្យសោកស្តាយជាខ្លាំង ព្រោះខ្ញុំមានជំនឿដ៏មុតមាំថា កិច្ចពិភាក្សារវាងអ្នករាយការណ៍ពិសេស និងរដ្ឋាភិបាល គួរតែផ្តោតជាសំខាន់លើខ្លឹមសារការងារដែលអង្គការសហប្រជាជាតិបានប្រគល់អាណត្តិឱ្យដោយមិនត្រូវផ្តោតលើរូបខ្ញុំជាលក្ខណៈបុគ្គលឡើយ។

ទោះជាយ៉ាងណាក៏ដោយ សម្រាប់ហេតុផលអ្វីក៏ដោយ វាទំនងជារដ្ឋាភិបាលបានផ្លាស់ប្តូរចិត្ត ហើយបានសហការជាមួយខ្ញុំ នៅក្នុងអំឡុងពេលបេសកកម្មរបស់ខ្ញុំមកកាន់មកប្រទេសកម្ពុជា នៅក្នុងខែឧសភា ឆ្នាំ២០១៣។ ខ្ញុំបានជួបជាមួយអ្នកពាក់ព័ន្ធជាច្រើន រួមមានសមាជិកជាន់ខ្ពស់របស់រដ្ឋាភិបាលដែលបានត្រៀមផ្តល់ព័ត៌មានផ្សេងៗ បានត្រៀមទទួលស្គាល់ភាពខ្វះខាតដែលកើតមាន និងមានឆន្ទៈក្នុងការធ្វើការជាមួយខ្ញុំ ក្នុងន័យស្ថាបនា ដើម្បីដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ទាក់ទងនឹងការការពារសិទ្ធិមនុស្សបានល្អប្រសើរជាងមុន លទ្ធិប្រជាធិបតេយ្យរឹងមាំថែមទៀត និងនីតិរដ្ឋពិតប្រាកដក្នុងប្រទេសកម្ពុជា។ ខ្ញុំមានការពេញចិត្តនឹងកម្រិតនៃការចូលរួម និងកិច្ចពិភាក្សាជាមួយដៃគូពិភាក្សារបស់រដ្ឋាភិបាល ព្រោះថាកិច្ចពិភក្សានេះបានធ្វើឡើង ដោយមានស្មោះត្រង់ ស្និទ្ធស្នាល និងក្នុងន័យស្ថាបនា។

ទន្ទឹមនឹងមានកិច្ចប្រជុំលក្ខណៈឯកជនជាមួយនឹងសមាជិកជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ប្រព្រឹត្តទៅក្នុងន័យស្ថាបនា ប្រការដែលគួរឲ្យសោកស្តាយនោះ គឺខ្ញុំបានទទួលរងនូវឧប្បត្តិហេតុអសកម្មមួយចំនួន។ ប្រសិនបើមើលរបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ឧប្បត្តិហេតុទាំងនោះត្រូវបានគេរៀបចំឡើង ដើម្បីបំភិតបំភ័យ និងយាយីរំខាន និងបង្វែរការយកចិត្តទុកដាក់របស់ខ្ញុំលើបញ្ហាសំខាន់ៗមួយចំនួន។ ខ្ញុំបានទទួលរងផងដែរ នូវការចោទប្រកាន់គ្មានមូលដ្ឋានអំពីភាពអគតិចំពោះរាជរដ្ឋាភិបាល។ ទាំងអស់នេះគឺជាការរិះគន់ស្រដៀងៗគ្នាជាខ្សែសង្វាក់ចំពោះការងាររបស់

អ្នករាយការណ៍ពិសេស និងមិនមានអ្វីដែលខុសប្លែកគ្នាខ្លាំងពីការប្រព្រឹត្តទៅលើបុព្វាធិការីមុនៗរបស់ខ្ញុំ កាលពីពេលកន្លងមកនោះទេ។ បើទោះជាខ្ញុំជួបប្រទះបទពិសោធន៍ដ៏ជូរចត់បែបនេះក្តី វាមិនបានធ្វើឲ្យខ្ញុំងាករេចេញពីគោលដៅនៃបេសកកម្មរបស់ខ្ញុំឡើយ ហើយខ្ញុំបានបន្តធ្វើការតស៊ូមតិសម្រាប់របៀបវារៈកំណែទម្រង់ស្ថាប័នជាតិដែលទទួលខុសត្រូវក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។

ជាការពិតណាស់ ប្រតិកម្មតបទៅនឹងឧប្បត្តិហេតុទាំងនេះ ដែលខ្ញុំបានទទួលសារគាំទ្រយ៉ាងច្រើនដ៏សន្ធឹកសន្ធាប់ ដល់ការងាររបស់ខ្ញុំនៅកម្ពុជាពីមនុស្សម្នាគ្រប់ស្រទាប់សង្គម ជាពិសេសយុវជន ដែលតាមរយៈនេះ ខ្ញុំមានការរំភើបចិត្តជាខ្លាំង។ សន្ទុះដែលយុវជនបានចូលសកម្មភាពគាំទ្រដល់រូបខ្ញុំ នៅចំពោះមុខនៃការយាយីមកលើរូបខ្ញុំ បានក្លាយជាកត្តាជំរុញមួយការទាមទារឲ្យមានការផ្លាស់ប្តូរក្នុងប្រទេសកម្ពុជា ដែលបញ្ជាក់ថា "វាគ្រប់គ្រាន់ហើយ"។ អនាគតរបស់ប្រទេសកម្ពុជា គឺពឹងផ្អែកលើយុវជន ដែលពួកគេបានបង្ហាញពីការប្តេជ្ញាចិត្តដ៏មុតមាំ ដើម្បីអះអាងអំពីសិទ្ធិរបស់ពួកគេ ហើយប្រយុទ្ធប្រឆាំងដើម្បីលទ្ធិប្រជាធិបតេយ្យ។ ការនេះបានធ្វើឲ្យមានការពេញចិត្ត និងរំភើបរីករាយជាខ្លាំង ។

ខ្ញុំជឿជាក់ថា នៅពេលដែលបុគ្គលណាម្នាក់ដាក់ខ្លួនដាក់កាយធ្វើការងារអ្វីមួយ ដើម្បីការពារសិទ្ធិមនុស្ស បុគ្គលនោះទំនងជាដឹងថា ខ្លួននឹងត្រូវប្រឈមនឹងការវាយប្រហារមកលើខ្លួនផ្ទាល់ និងការចោទប្រកាន់ដោយអយុត្តិធម៌អំពីភាពលំអៀង។ ខ្ញុំបានដឹងអំពីបញ្ហានេះ នៅពេលដែលខ្ញុំបានស្ម័គ្រចិត្តទទួលយកមុខតំណែងនេះ។ អ្នកដែលឆ្លាត នឹងសម្របសម្រួលខ្លួនទៅតាមពេលវេលា និងទទួលយកការផ្លាស់ប្តូរ។ អ្នកដែលមិនស្តាប់ការអំពាវនាវនឹងធ្វើអ្វីមួយដោយការប្រថុយប្រថានរបស់ខ្លួន ដោយសារការផ្លាស់ប្តូរជំរុញឲ្យពួកគេធ្វើយ៉ាងឆាប់រហ័ស។ ភាពជាអ្នកដឹកនាំគឺនិយាយអំពីការគ្រប់គ្រងការផ្លាស់ប្តូរ តាមរយៈកំណែទម្រង់ ជាជាងប្រឆាំងទប់ទល់នឹងវា។ ខ្ញុំយល់ឃើញថាអ្នកដែលដើរផ្លូវខុសពីប្រវត្តិសាស្រ្ត នឹងត្រូវប្រវត្តិសាស្រ្តដាក់ទោសទណ្ឌ។

**លោក ប្រធាន ជាទីគោរពរាប់អាន**

ចាប់តាំងពីខ្ញុំបានបញ្ចប់របាយការណ៍របស់ខ្ញុំ នៅថ្ងៃទី២៣ ខែកក្កដា ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតទូទៅមួយ នៅថ្ងៃទី២៨ ខែកក្កដា និងបានឃើញការវិវឌ្ឍន៍មួយចំនួនដែល

មិនធ្លាប់មានពីមុនមក។ ចំណាប់អារម្មណ៍ដែលខ្ញុំមាននោះ គឺថា កំណើតនយោបាយថ្មី ផ្តើមមាន នៅក្នុងប្រទេស និងការផ្លាស់ប្តូរ ហាក់បីដូចជាកើតមានយ៉ាងឆាប់រហ័ស ដែលគេអាចព្យាករ សូម្បី តែកាលពីមួយឆ្នាំកន្លងទៅ នៅពេលដែលខ្ញុំបានថ្លែងការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នៅក្នុងសេចក្តីថ្លែងការណ៍នេះ ខ្ញុំមានបំណងចាប់យកការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រមួយចំនួន នៅ ក្នុងទិដ្ឋភាពនយោបាយនៅក្នុងប្រទេស ដែលបានធ្វើឡើងនៅមុនពេល នៅក្នុងពេល និងនៅបន្ទាប់ ពីការបោះឆ្នោត។

វិធានការសំខាន់ៗមួយចំនួន ដែលបានចាត់ឡើង ក្នុងទិសដៅវិជ្ជមានមួយ នៅមុនពេល បោះឆ្នោត មានដូចជា ដោះលែងលោកម៉ម សូណង់ដូ ដែលជាអ្នកការពារសិទ្ធិមនុស្សដែលលេច ធ្លោមួយរូប និងការផ្តល់ការលើកលែងទោសដល់មេដឹកនាំគណបក្សប្រឆាំង គឺលោក សម រង្ស៊ី ដែលត្រូវសត្រាយផ្លូវឲ្យគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញ បន្ទាប់ពី ការនិរទេសខ្លួននៅប្រទេស បារាំង ដើម្បីចូលរួមក្នុងដំណើរការនយោបាយ។ ការបោះឆ្នោតមួយដែលបានធ្វើឡើង ប្រកបដោយ សន្តិវិធីភាគច្រើន និងចំណុចសំខាន់នៃបញ្ហានេះ មិនអាចបរិយាយអស់។

ទោះបីជាយ៉ាងណាក៏ដោយ កំណត់សំគាល់សុទិដ្ឋិនិយមរបស់ខ្ញុំមានការធ្លាក់ចុះទៅវិញ ដោយមានការចោទប្រកាន់ពីភាពមិនប្រក្រតីនៃការបោះឆ្នោតជាច្រើន ព្រមទាំងការបរាជ័យរបស់ រដ្ឋាភិបាល និង គណៈកម្មការជាតិរៀបចំការបោះឆ្នោត ក្នុងការសម្របសម្រួលឲ្យមានការស៊ើប អង្កេតពីភាពមិនប្រក្រតីជាបន្ទាន់ ដោយអព្យាក្រឹត្យ តម្លាភាព ជឿទុកចិត្ត និង ហ្មត់ចត់។ ទន្ទឹម ដែលខ្ញុំស្វាគមន៍ការតាំងចិត្តរបស់អាជ្ញាធរដែលគោរពរដ្ឋធម្មនុញ្ញ ព្រមទាំងស្ថាប័ន និង យន្តការ ដែលបង្កើតឡើងតាមរដ្ឋធម្មនុញ្ញ ខ្ញុំសូមបញ្ជាក់ថា ការប្រកាន់ខ្ជាប់នូវរដ្ឋធម្មនុញ្ញមានអត្ថន័យច្រើន លើសពីនេះទៀត។ ផ្នែកនៃរដ្ឋធម្មនុញ្ញដែលត្រូវគោរពសំខាន់ជាគេនោះ គឺតម្លៃដែលរបស់រដ្ឋ ធម្មនុញ្ញដែលចែងពីការគោរពសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូររបស់មនុស្ស និង លទ្ធិប្រជាធិបតេយ្យ។ ការទទូចចង់បានការអនុវត្តតាមយន្តការលទ្ធិប្រជាធិបតេយ្យផ្លូវការតែមួយមុខតាមគោលការណ៍សិទ្ធិ មនុស្សជាមូលដ្ឋាន គឺជាការបដិសេធនូវគោលបំណងពិតប្រាកដរបស់រដ្ឋធម្មនុញ្ញ។ ការទទូចចង់ បានណាមួយដែលថា មានតែយន្តការដែលមានស្រាប់អាចដោះស្រាយបណ្តឹងបាន ទោះបីយន្តការ ទាំងនេះគ្មានលទ្ធភាពផ្តល់យុត្តិធម៌ និង តម្លាភាពបានក៏ដោយ តាមទសន្សនៈរបស់ខ្ញុំ វាគ្រាន់ តែជាការបញ្ជាក់ពីតម្រូវការឲ្យមានកំណែទម្រង់ វាមិនមែនបញ្ជាក់ពីការបដិសេធទេ។ នៅក្នុងទំ

នាក់ទំនងនេះ ខ្ញុំសូមរំលឹកពីអនុសាសន៍របស់ខ្ញុំអំពីកំណែទម្រង់ការបោះឆ្នោតដែលបានបញ្ចូលក្នុងរបាយការណ៍របស់ខ្ញុំដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៅឆ្នាំ ២០១២ ដែលភាគច្រើននៃអនុសាសន៍នេះមិនបានអនុវត្តតាម មុនការការបោះឆ្នោតឡើយ។

គ្រប់ប្រទេសណាដែលស្ថិតក្នុងស្ថានភាពអន្តរកាលនៃលទ្ធិប្រជាធិបតេយ្យ ប្រឈមមុខនឹងពេលវេលាមួយដែលត្រូវមានការផ្លាស់ប្តូរការគ្រប់គ្រង។ ឥឡូវនេះ ប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងពេលវេលាបែបនេះ។ ប៉ុន្តែ ជាចុងក្រោយ លទ្ធផលបោះឆ្នោតផ្លូវការ និង មានភាពមិនប្រក្រតី បង្ហាញឲ្យឃើញថា ប្រជាពលរដ្ឋជាងពាក់កណ្តាលបោះឆ្នោតឲ្យគណបក្សមួយ ហើយប្រជាពលរដ្ឋក្រោមពាក់កណ្តាលបោះឆ្នោតឲ្យគណបក្សមួយទៀត។ ដើម្បីឲ្យរដ្ឋសភាក្លាយជាសភាតំណាងឲ្យប្រជាពលរដ្ឋកម្ពុជាទាំងមូលពិតប្រាកដ និង ដើម្បីអាចឲ្យមានការសន្និដ្ឋានថា សិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋត្រូវបានអនុវត្តដោយមានប្រសិទ្ធភាពនៅថ្ងៃទី ២៨ ខែ កក្កដា វាជាការចាំបាច់ណាស់ដែលរដ្ឋសភាមានសមាសភាពពីគណបក្សជាប់ឆ្នោតទាំងពីរ។

ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំកត់សំគាល់ឃើញថា ការបើកប្រជុំរដ្ឋសភាពីម្សិលមិញមានការចូលរួមពីគណបក្សតែមួយប៉ុណ្ណោះ។ការមិនពេញចិត្តនឹងការដោះស្រាយបណ្តឹងអំពីភាពមិនប្រក្រតីនៃការបោះឆ្នោត ធ្វើឲ្យគណបក្សប្រឆាំងធ្វើពហិការមិនចូលរួមការបើកការប្រជុំនេះ។ ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងចំពោះបរាជ័យរបស់គណបក្សទាំងពីរក្នុងការព្រមព្រៀងគ្នាមុនថ្ងៃម្សិលមិញ ហើយខ្ញុំកាន់តែមានការសោកស្តាយយ៉ាងខ្លាំងថែមទៀតដែលថា ការបើកប្រជុំនេះនៅតែបានដំណើរការ។

គណបក្សមួយបានបំប៉ោងគំនិតពីការបែងចែកអសនៈឡើងវិញ ដែលទទួលបានដោយស្របច្បាប់ដោយគណបក្សប្រឆាំង តាមការបោះឆ្នោតឲ្យគណបក្សនយោបាយមួយទៀត។ ខ្ញុំសូមបញ្ជាក់ថា ចំណុចនេះពុំមានមូលដ្ឋាននៅក្នុងច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិឡើយ។

អាជ្ញាធរអាចឆ្លៀតឱកាសបង្ហាញថា ពួកគេបានយល់ពីឆន្ទៈរបស់ប្រជាពលរដ្ឋយ៉ាងហោចណាស់ពាក់កណ្តាល ដែលបានបោះឆ្នោតឲ្យមានការផ្លាស់ប្តូរដោយដឹកនាំការខិតខំប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់ ដោយបញ្ចូលនូវការផ្លាស់ប្តូរយ៉ាងលំបាកដែលចាំបាច់ឲ្យប្រទេសធ្វើទំនើបកម្ម ឬ ក៏វាអាចសម្រេចថា វាចាំបាច់ក្នុងការបំបាត់ការមិនពេញចិត្ត ដែលនឹងបង្កើតឡើងដោយសារផលលំបាកទាំងនោះ។ ដូចគ្នានេះដែរ គណបក្សប្រឆាំងបានប្រកាន់ភ្ជាប់ និង ផ្តោតលើឆន្ទៈរបស់ប្រជាពល

រដ្ឋដែលចង់បានការផ្លាស់ប្តូរតាមវិធីមួយដែលមិនធ្លាប់ឃើញមានពីមុនមកនៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់ប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ពិតប្រាកដនៃការជោគជ័យនៅតែមើលឃើញដដែល។ ទន្ទឹមនឹងភាពមិនប្រក្រតីត្រូវតែដោះស្រាយនោះ គណបក្សប្រឆាំងត្រូវតែលើកឡើងបង្ហាញផងដែរ ខ្លួនមានផែនការច្បាស់លាស់ក្នុងការសម្រេចបាននូវអ្វីដែលខ្លួនបានសន្យា។ ដើម្បីដោះស្រាយនូភាពជាប់គាំងបច្ចុប្បន្នដោយគ្មានការយឺតយ៉ាវបន្តទៀតនោះ ខ្ញុំសូមជំរុញឲ្យមានការបន្តការពិភាក្សា នៅក្នុងថ្នាក់សមស្របណាមួយដែលអាចធ្វើសេចក្តីសម្រេចបាន។

ដោយសារប្រជាពលរដ្ឋកម្ពុជាធ្លាប់ជួយប្រទអំឡុងពេលមិនច្បាស់លាស់ ក្រោយការបោះឆ្នោត ប្រជាពលរដ្ឋកម្ពុជាភាគច្រើនមានសេចក្តីសង្ឃឹមយ៉ាងជ្រាលជ្រៅថា ស្ថានភាពនេះនឹងមានសន្តិភាព។ ដូច្នេះ វាមានការភ្ញាក់ផ្អើលដែលថា គ្រាន់តែមួយសប្តាហ៍កន្លងមក ខណៈពេលដែលពលរដ្ឋសាមញ្ញនៅភ្នំពេញ បានសំដែងការមិនពេញចិត្តតាមផ្លូវម្តងទៀត ស្រាប់តែកងកម្លាំងសន្តិសុខប៉ះទង្គិចជាមួយអ្នកតវ៉ា ដែលនាំឲ្យអ្នកនៅក្បែរហេតុការណ៍នោះបានស្លាប់ម្នាក់ និង របួសជាច្រើនម្នាក់ថែមទៀត។ ទន្ទឹមនឹងខ្ញុំកត់សំគាល់ពីភាពរឹតត្បិតជាទូទៅរបស់អាជ្ញាធរក្នុងការប្រើប្រាស់កម្លាំងក្នុងសប្តាហ៍កន្លងមកនេះ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងនូវអ្វីដែលហាក់ដូចជាមានការប្រើប្រាស់កម្លាំងដោយមិនរើសមុខ និង យ៉ាងខ្លាំងក្លា ទៅលើអ្នកតវ៉ាក្នុងស្ថានភាពនេះ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះរបាយការណ៍ដែលថា កងកម្លាំងសន្តិសុខបានបាញ់គ្រាប់ពិត ហើយពេលខ្លះបាញ់ចូលហ្វូងមនុស្ស ហើយមនុស្សជាច្រើន រួមទាំងយុវជនត្រូវបានវាយដំយ៉ាងខ្លាំងដោយដំបង។ ខ្ញុំក៏មានការព្រួយបារម្ភពីការដែលមន្ត្រីកងរាជអាវុធហត្ថរាប់រយនាក់បណ្តេញដោយបង្ខំលើការជួបជុំគ្នាដោយសន្តិវិធីអំពីការធ្វើកូដកម្មអត់អាហាររបស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ នៅវត្តភ្នំកាលពីថ្ងៃសុក្រមុន។ លើសពីនេះ ខ្ញុំក៏មានការព្រួយបារម្ភដោយមានរបាយការណ៍ថា នៅយប់នៅថ្ងៃទី ២២ ខែ កញ្ញា មានការជួបជុំដោយសន្តិវិធីរបស់សកម្មជនដែលតវ៉ាប្រឆាំងនឹងការបណ្តេញដោយបង្ខំនៅតំបន់បឹងកក់ ត្រូវបានបំបែកដោយបង្ខំដោយមនុស្សមួយក្រុមស្លៀកពាក់ស៊ីវិល ដែលគេមើលឃើញថាមានការសម្របសម្រួលជិតស្និទ្ធពីនគរបាលដែលមានវត្តមាន។ គេនិយាយថា ប្រហែលមានមនុស្សរាប់សិបនាក់ត្រូវបានគេវាយដំ បាញ់គ្រាប់ឃ្លីដោយជំពាម និង វាយដោយប្រើកាំភ្លើងឆក់ និង ដំបងឆក់។

នៅក្នុងលក្ខខណ្ឌដ៏ខ្លាំងក្លាំងតាមដែលអាចមាននោះ ក្នុងការជំរុញអាជ្ញាធរឈប់ប្រើប្រាស់អំពើហិង្សាថែមទៀត ខ្ញុំសូមបញ្ជាក់ថា ការជួបជុំគ្នាដោយសន្តិវិធីគឺសិទ្ធិមនុស្ស ដែលទទួលការរឹតត្បិតណាដែលមានការចាំបាច់បំផុតនៅក្នុងសង្គមប្រជាធិបតេយ្យ។ទន្ទឹមនឹងការអនុវត្តច្បាប់មានភារកិច្ចធានាសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ ពួកគេត្រូវប្រយ័ត្នប្រយែងថា ការប្រើប្រាស់កម្លាំងណាមួយត្រូវស្ថិតក្រោមគោលការណ៍សកល ដូចជា នីត្យានុកូលភាព ភាពចាំបាច់ និង សមាមាត្រ។ ខ្ញុំក៏សូមអំពាវនាវឲ្យអាជ្ញាធរអនុញ្ញាតឲ្យមានបាតុកម្មណាមួយដែលមានការគ្រោងទុក និង ពិសេស ជីវភាពប្រចាំថ្ងៃ ដោយគ្មានការរឹតត្បិតថែមទៀតឡើយ។ ចំពោះចំណុចនេះ ខ្ញុំមានការសោកស្តាយដោយត្រូវនិយាយថា វាហាក់ដូចជាមិនទាន់មានស្វែងយល់នៅក្នុងប្រទេសកម្ពុជាដែលថា ផ្នែកនៃដំណើរការប្រជាធិបតេយ្យនោះ គឺឲ្យមនុស្សទាំងអស់អាចសំដែងទស្សនៈរបស់គេដោយសេរី ហើយតួនាទីរបស់រដ្ឋក្នុងបាតុកម្មដោយសន្តិវិធីគឺត្រូវសម្របសម្រួល មិនមែនរំខានគេនោះទេ។

ដោយនិយាយបែបនេះ ខ្ញុំសូមបន្តជឿថា អ្នកដឹកនាំប្រទេសកម្ពុជា សូម្បីតែនៅដំណាក់កាលយឺតយ៉ាងបែបនេះក៏ដោយ នៅតែធ្វើឲ្យការបោះឆ្នោតនេះក្លាយព្រឹត្តិការណ៍សំខាន់នៅក្នុងដំណើរផ្លូវមួយដែលធ្វើឲ្យប្រទេសកម្ពុជាក្លាយជាសង្គមយុត្តិធម៌ សមធម៌ និង សេរី។ ខ្ញុំមានសេចក្តីសង្ឃឹមដោយស្មោះត្រង់ថា នៅក្នុងដំណើរការនេះ ស្ថានភាពនឹងត្រូវដោះស្រាយដោយមិនបង្កឲ្យរបួស ឬ បាត់បង់ជីវិតថែមទៀតឡើយ ហើយឆន្ទៈរបស់ប្រជាពលរដ្ឋនឹងត្រូវឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចថ្មីដែលនឹងនាំឲ្យប្រទេសនេះធ្វើដំណើរលើផ្លូវទៅរកលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

នេះគឺជាអ្វីដែលខ្ញុំបានដឹងក្នុងអំឡុងពេលបោះឆ្នោតវិសាមញ្ញនេះ ដែលធ្វើឲ្យខ្ញុំមានសេចក្តីសង្ឃឹមបាន។ ខ្ញុំបានព្យាករតាំពីបីខែមុនមកហើយថា មេដឹកនាំគណបក្សប្រឆាំងនឹងទទួលបានការលើកលែងទោសពីព្រះមហាក្សត្រ ដោយអនុញ្ញាតឲ្យចូលប្រទេសកម្ពុជាវិញ ហើយកញ្ចប់ឆ្នោតសុវត្ថិភាពនឹងត្រូវបានបញ្ជាឲ្យបើក ឬ បាតុកម្មមហាជននឹងត្រូវបានអនុញ្ញាតឲ្យធ្វើឡើងដោយគ្មានការរារាំង រហូតដល់ព្រឹត្តិការណ៍ថ្មីៗនេះ។

ដោយមានវិវដ្តគួរឲ្យចាប់អារម្មណ៍ទាំងមូលបែបនេះ ខ្ញុំសង្ឃឹមថា សិទ្ធិមនុស្ស យុត្តិធម៌ និង តម្លាភាពនៅប្រទេសកម្ពុជា នឹងពិតជាត្រូវបានពង្រឹងដោយមានអត្ថន័យ។ ក្នុងការធ្វើដូច្នេះ អ្វីដែលចាំបាច់ មិនមែនជាកាយវិការឆន្ទានុសិទ្ធិទេ ប៉ុន្តែវាជាវិធានត្រឹមត្រូវ ដែលត្រូវអនុវត្តដោយត្រឹមត្រូវ។

សេចក្តីថ្លែងការណ៍រួមស្តីពីការប្តេជ្ញាចិត្តរបស់គណបក្សនយោបាយទាំងពីរក្នុងការទទួលបានកំណែទម្រង់ច្បាស់លាស់ក្នុងវិស័យជាអាទិភាព នឹងធ្វើដំណើរវែងឆ្ងាយក្នុងការធានាដល់សហគមន៍អន្តរជាតិ និង ពលរដ្ឋកម្ពុជា ដែលថា ចុងបញ្ចប់ ប្រទេសនេះពិតជាកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ។ របាយការណ៍របស់ខ្ញុំស្តីពីកំណែទម្រង់ស្ថាប័នតុលាការ សភា និង ការបោះឆ្នោត គឺជាការណែនាំសម្រាប់សមាជិកសភាមកពីគណបក្សនយោបាយទាំងពីរ។

ខ្ញុំមានការសោកស្តាយដែលពេលវេលាមិនអនុញ្ញាតឲ្យខ្ញុំបានផ្តល់ការពន្យល់អំពីបញ្ហាសិទ្ធិមនុស្សបន្ទាន់ដូចគ្នាផ្សេងទៀតនៅប្រទេសកម្ពុជា ជាពិសេស សិទ្ធិដីធ្លី និង សិទ្ធិលំនៅឋាន សិទ្ធិការងារ និទណ្ឌភាព សេរីភាពទទួលព័ត៌មាន និង សិទ្ធិផ្សេងទៀត ដែលប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ។ នៅទីនេះ ខ្ញុំសូមអោយក្រុមប្រឹក្សាសិទ្ធិមនុស្សពិនិត្យមើលរបាយការណ៍របស់ខ្ញុំ។

**លោកប្រធានជាទីគោរពរាប់អាន**

ជាសរុបមក ខ្ញុំសូមវាយតម្លៃថា ប្រទេសកម្ពុជាបានធ្វើដំណើរក្នុងផ្លូវដ៏វែងឆ្ងាយ ចាប់ពីចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ ១៩៩១ និង អនុម័តរដ្ឋធម្មនុញ្ញថ្មី ដែលឈរលើមូលដ្ឋាននៃតម្លៃលទ្ធិប្រជាធិបតេយ្យសេរី នៅឆ្នាំ ១៩៩៣។ ប៉ុន្តែ ប្រទេសកម្ពុជានៅតែត្រូវធ្វើដំណើរទៅទៀតក្នុងការលើកកម្ពស់ និង ការពារសិទ្ធិមនុស្ស ពង្រឹងអភិបាលកិច្ចល្អ ព្រងឹងឯករាជ្យភាព និង សមត្ថភាពរបស់ស្ថាប័នរដ្ឋដែលទទួលបន្ទុកផ្នែកគោរពសិទ្ធិមនុស្ស។ ខ្ញុំមានការរីករាយចំពោះការទទួលស្គាល់ដោយស្មោះត្រង់អំពីបញ្ហានេះពីដៃគូពិភាក្សាខាងរដ្ឋាភិបាលក្នុងអំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំនៅខែឧសភា នៅឆ្នាំ ២០១៣។

សហគមន៍អន្តរជាតិបានដាក់វិនិយោគទុនយ៉ាងច្រើននៅក្នុងប្រទេសកម្ពុជា ចាប់ពីចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និង ការបោះឆ្នោតបែបប្រជាធិបតេយ្យលើកដំបូង ដែលស្ថិតក្រោមការជួយឧបត្ថម្ភរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ឆ្នាំ ១៩៩៣។ បំណងប្រាថ្នារបស់រដ្ឋជាភាគីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និង អ្នកពាក់ព័ន្ធជាតិ ដែលបានចូលរួមក្នុងសន្និសីទស្តីពីប្រទេសកម្ពុជា គឺចង់ឃើញការវិវដ្តនៃលទ្ធិប្រជាធិបតេយ្យសេរី។ដោយបានឃើញអាជ្ញាធរដែលបានធ្វើការរឹតត្បិតយ៉ាងខ្លាំងក្នុងរយៈពេលជាច្រើនសប្តាហ៍ម្តងទៀត ដែលងាកទៅរកយុទ្ធវិធីចាស់ ដែលជាការរំលោភបំពានលើសិទ្ធិពលរដ្ឋជាមូលដ្ឋាននៅក្នុងរយៈពេលពីរបីថ្ងៃកន្លងមកនេះ ខ្ញុំជឿជាក់ថា វាជាការច្បាស់ណាស់ដែលថា ប្រទេសកម្ពុជាសព្វថ្ងៃ

កំពុងស្ថិតនៅលើផ្លូវបំបែក។ នៅទីនេះ ខ្ញុំមើលឃើញតួនាទីដ៏សំខាន់របស់សហគមន៍អន្តរជាតិ រួមទាំងអាណត្តិរបស់ខ្ញុំផងដែរ ក្នុងការបន្តជួយឲ្យប្រជាពលរដ្ឋ និង រដ្ឋាភិបាលកម្ពុជាធ្វើដំណើរឆ្ពោះទៅលទ្ធិប្រជាធិបតេយ្យសេរីពេញលេញជាងនេះ ដែលបានបញ្ជាក់ដោយសន្តិភាពដោយនិរន្តរភាព និង ការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយសមធម៌។

**សូមអរគុណចំពោះការយកចិត្តទុកស្តាប់។**

===============